ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

# អនុស្សរណៈយោគយល់

រវាង

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
(គ.ជ.ប.ជ)

និង

## អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia ACTs)

ស្តីពី

## កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស

# បុព្វកថា

**ដោយហេតុថា** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសម្តែងនូវបំណងប្រាថ្នា ក្នុងការរួមសហការជាមួយអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជាក្នុងសកម្មភាពមនុស្សធម៌ (កិច្ចការពារកុមាររងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ រួមទាំងកុមារដែលមាន សភាពមិនប្រក្រតី) នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការ ដើម្បីចូលរួមសកម្មភាព មនុស្សធម៌។

**ដោយហេតុថា** គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា នឹងសហការគ្នាយ៉ាងជិតស្និទ្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសទៅលើអនីតិជន។

**ដោយយល់ថា** បច្ចុប្បន្នបានកើតចេញនូវបទល្មើសថ្មីៗពាក់ព័ន្ធកុមារ ដូចជាការពពោះជំនួស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ/អ៊ីនធឺណិត ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស ទើបគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានព្រមព្រៀង រួមសហការដើម្បីអនុវត្តកម្មវិធីមនុស្សធម៌ក្នុងកិច្ចការពារកុមាររងគ្រោះដូចខាងក្រោម ៖

## ប្រការ១
## គោលបំណង

អនុស្សរណៈយោគយល់នេះ មានគោលបំណងធ្វើសកម្មភាពលើកស្ទួយសិទ្ធិជាមូលដ្ឋានរបស់កុមារពិសេសសកម្មភាពមនុស្សធម៌ ដើម្បីជួយដល់កុមារដែលងាយរងគ្រោះ និងរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៅតាមរាជធានី និងខេត្តគោលដៅចំនួន ២១ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (ដែលមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ) និងគោលដៅរបស់អង្គការដៃគូនៅខេត្តត្រាត រ៉ាក់យ៉ង និងសមុទ្រសាខន នៃព្រះរាជាណាចក្រថៃ ក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ដោយអនុលោមតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

# ប្រការ ២
# ការទទួលខុសត្រូវរបស់
# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# (គ.ជ.ប.ជ)

១. សហការ និងចាត់វិធានការសម្របសម្រួលទាន់ពេលវេលាក្នុងការអន្តរាគមន៍ជួយសង្គ្រោះ កុមាររងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងករណីទទួលបានព័ត៌មានពីអង្គការសម្ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា (Cambodia ACTs)។

២. ធ្វើការសម្របសម្រួល ជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តគោលដៅ (គ.ខ.ប.ជ) ក្នុងការគាំទ្រឱ្យអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារ នៅកម្ពុជា អង្គការជាសមាជិក និងអង្គការដៃគូ ក្នុងការអនុវត្តសកម្មភាពអប់រំផ្សព្វផ្សាយឯកសារខ្លឹមសារ ដែលមានការអនុញ្ញាតពី គ.ជ.ប.ជ និងការបណ្តុះបណ្តាលមេរៀនដែលពាក់ព័ន្ធការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាពនៅតាមរាជធានីខេត្តគោលដៅ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

៣. អនុញ្ញាតឱ្យ អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា ចូលរួមកិច្ចប្រជុំ ដែលរៀបចំដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង០៦ របស់ គ.ជ.ប.ជ ដើម្បីចែករំលែកព័ត៌មានបទពិសោធន៍ និងសមិទ្ធផលការងារដែល ទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពាក់ព័ន្ធសកម្មភាពមនុស្សធម៌លើកុមារ។

# ប្រការ ៣
# ការទទួលខុសត្រូវរបស់អង្គការសម្ព័ន្ធអង្គការ
# មិនមែនរដ្ឋាភិបាល ប្រឆាំងការជួញដូរកុមារនៅកម្ពុជា

១. សហការជាមួយអង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធនៅក្នុងប្រទេសថៃ និងកម្ពុជា ជាពិសេស ក្រុមការងារបង្ការទប់ស្កាត់របស់ គ.ជ.ប.ជ ដើម្បីឱ្យកុមារកម្ពុជាបានរៀនភាសាជាតិរបស់ខ្លួនក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ ជាមួយឳពុកម្តាយ ឬអាណាព្យាបាលនៅក្នុងប្រទេសថៃ ដោយជំរុញឱ្យមានគ្រូស្ម័គ្រចិត្ត ដើម្បីបង្រៀនតាមកម្មវិធីសិក្សាដែលបានព្រមព្រៀងគ្នារវាង ក្រសួងអប់រំនៃប្រទេសទាំងពីរ (កម្ពុជា-ថៃ)។

២. សហការជាមួយអង្គការដៃគូដើម្បីស្រាវជ្រាវ និងធ្វើការបង្ហាញដល់ស្ថាប័នពាក់ព័ន្ធនូវរបកគំហើញមួយចំនួនអំពីស្ថានភាពកុមារចំណាកស្រុក និងការជួញដូរមនុស្សពីប្រទេសកម្ពុជាទៅ ប្រទេសថៃ និងពីប្រទេសថៃមកប្រទេសកម្ពុជា។

៣. រៀបចំដំណើរទស្សនកិច្ចកម្ពុជា-ថៃ និងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក។

៤. ចូលរួមជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជាពិសេសក្រុម ការងារជំនាញអន្តរក្រសួង-ស្ថាប័នទាំង០៦ ជាសមាជិករបស់ គ.ជ.ប.ជ អង្គការជាតិ និងអន្តរជាតិ ក្នុងការរួមចំណែកកសាងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឯកសារពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។

៥. ពង្រឹងបណ្តាញអង្គការសមាជិក និងដៃគូរបស់ខ្លួននៅតាមរាជធានី ខេត្តគោលដៅដើម្បីអនុវត្តការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពិសេសអនីតិជនឱ្យមានប្រសិទ្ធភាពដោយអនុលោមតាមផែនការយុទ្ធសាស្ត្រជាតិ។

៦. ចូលរួមសហការជាមួយ គ.ជ.ប.ជ ឬ គ.ខ.ប.ជ និងអង្គការជាសមាជិក ក្នុងការរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សនៅថ្ងៃទី ១២ ខែធ្នូ និងវេទិកាអន្តរសាសនាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជារៀងរាល់ឆ្នាំ។

៧. គោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងចូលរួមតែក្នុងសកម្មភាពមនុស្សធម៌ ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផលប្រយោជន៍សាធារណៈ និងសុខុមាលភាពសង្គម ជៀសវាងដាច់ខាតការចូលរួមពាក់ព័ន្ធគ្រប់សកម្មភាពនយោបាយ។

## ប្រការ ៤
## ការដោះស្រាយវិវាទ

រាល់វិវាទដែលអាចកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តអនុស្សរណៈយោគយល់នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា ត្រូវដោះស្រាយតាមរយៈការចរចាដោយសន្តិវិធីរវាងភាគីទាំងពីរ។

## ប្រការ ៥
## អវសានប្បញ្ញត្តិ

អនុស្សរណៈយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល ៣(បី)ឆ្នាំ ហើយអាចបន្តសុពលភាពបានទៀតដោយមានការយល់ព្រមពីភាគីទាំងពីរ។

ភាគីម្ខាងអាចជូនដំណឹងទៅភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ ក្នុងពេលណាក៏បាន ប្រសិនបើខ្លួនមានបំណងបញ្ចប់អនុស្សរណៈយោគយល់គ្នានេះ។ ក្នុងករណីនេះ អនុស្សរណៈយោគយល់នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងមួយច្បាប់ជាភាសាខ្មែរ។

**ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...៣០.....ខែ....ធ្នូ.........ឆ្នាំ២០២០**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**
**អនុប្រធានអចិន្ត្រៃយ៍**

លោកជំទាវ **ជូ ប៊ុនអេង**

**អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា**
**ប្រធានក្រុមប្រឹក្សាភិបាល**

លោកស្រី **ហ៊ុន ផាណ្ណា**

# ឧបសម្ព័ន្ធ

## សង្ខេបអំពីគម្រោង

- ឈ្មោះស្ថាប័ន ៖ **អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា** (Cambodia ACTs)
- ប្រភេទស្ថាប័ន ៖ ជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាជិកចំនួន១៦ អង្គការ/សមាគម ជាដៃគូបាននឹងកំពុងធ្វើសកម្មភាពក្នុងខេត្ត ចំនួន ២១ និងរាជធានីភ្នំពេញ។
- បានចុះបញ្ជីនៅក្រសួងមហាផ្ទៃចុងក្រោយលេខ ៣០១៦សជណ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ។
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ បុរីវិទ្ធិទួលសង្កែ ផ្ទះលេខ K0៩ ផ្លូវលេខ K១0 សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ
- ទូរស័ព្ទ ៖ (+៨៥៥) ៦១ ៣៣៦ ២២៦
- អ៊ីម៉ែល ៖ sg@cambodiaacts.org
- ឈ្មោះគម្រោង ៖ បញ្ឈប់ការកេងប្រវ័ញ្ចនានា តាមរយៈការទទួលបាននូវសេវាសង្គម
- ថវិកាអនុវត្តគម្រោង ៖ ១៨៤ ៩១១ ដុល្លារ
- កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (បានចុះកិច្ចសហការនៅថ្ងៃ..............)
- កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២២
- ទីកន្លែងអនុវត្តគម្រោង ៖ រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ខេត្តកំពត ខេត្តតាកែវ ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី នៃព្រះរាជាណាចក្រកម្ពុជា និងសហការជាមួយដៃគូ ដែលធ្វើការនៅខេត្តត្រាត សមុទ្រសាខន វ៉ាក់យ៉ង នៃព្រះរាជាណាចក្រថៃ។
- ចំនួនបុគ្គលិកបរទេស ៖ គ្មាន
- ចំនួនបុគ្គលិកខ្មែរ ៖ ០៤ នាក់